ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១១២០ សហវ.នគលក

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៧

**ជម្រាបជូន**
**លោកនាយកសាលាជាតិកសិកម្មព្រែកលៀប**

**កម្មវត្ថុ** : ករណីសំណើសុំការអនុញ្ញាតលទ្ធផលដេញថ្លៃ និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ភី អេស ឌី អិន ខមមើស ស្ដីពីការងារជួសជុលអគារសិក្សាទំហំ ៧៣០ម² កំពស់៣ជាន់ ប្រចាំឆ្នាំ២០១៧ ។

**យោង** :
- លិខិតលេខ៥២៨៦ សហវ.អថ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុបើកឯកសារដេញថ្លៃចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ របស់គណៈកម្មាធិការលទ្ធកម្ម សាលាជាតិកសិកម្មព្រែកលៀប
- កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យាចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧ របស់គណៈកម្មាធិការលទ្ធកម្ម សាលាជាតិកសិកម្មព្រែកលៀប
- លិខិតលេខ៦១៧ ក.ព.ល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ របស់សាលាជាតិកសិកម្មព្រែកលៀប ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកនាយកមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយល់ព្រមតាមសំណើរបស់សាលាជាតិកសិកម្មព្រែកលៀប ប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន **ភី អេស ឌី អិន ខមមើស** ដើម្បីជួសជុលអគារសិក្សាទំហំ ៧៣០ម២ កំពស់៣ជាន់ ប្រចាំឆ្នាំ២០១៧ ដែលមានទឹកប្រាក់សរុប ១ ០៤៥ ០០០ ០០០ រៀល (មួយប៊ីលាន សែសិបប្រាំលានរៀលគត់) ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកនាយកមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមលោកនាយកទទួលនូវការរាប់អានពីខ្ញុំ ។

ស. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ប្រតិភូរាជរដ្ឋាភិបាល...

ង៉ែត សុវណ្ណ

**ចម្លងជូន:**
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមហ៊ុន ភី អេស ឌី អិន ខមមើស
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798